# អរិយធម៌ខារ៉ាល ( Caral Civilization)

អរិយធម៌ខារ៉ាល ឬខារ៉ាល សួពេ ( Caral Supe) ត្រូវបានអ្នកស្រាវជ្រាវស្គាល់ដំបូងនៅដើមស.វ.ទី២០ តាមរយៈការរកឃើញនូវក្រុមសំណង់ប្រាសាទពីរ៉ាមីត ដែលហៅថាពីរ៉ាមីត ខារ៉ាល( Pyramid of Caral) មានចំនួន៧ដែលកប់នៅក្រោមវាលខ្សាច់ៗ[១]

តំបន់ពីរ៉ាមីត ខារ៉ាល មានទីតាំងស្ថិតនៅតំបន់វាលខ្សាច់នៃជ្រលងភ្នំសួពេ ក្បែរទីក្រុងខារ៉ាល និងមានចម្ងាយប្រមាណ១៨០គីឡូពី រាជធានីលីម៉ា ប្រទេសពេរ៉ូៗ[២] អ្នកស្រាវជ្រាវបុរាណវិទ្យាបានចាប់ផ្តើមធ្វើកំណាយនៅទីនោះក្នុងអំឡុងឆ្នាំ១៩៩៦ និងបន្តរហូតដល់សព្វថ្ងៃដោយអ្នកបុរាណវិទូជនជាតិប៉េរូ ម្នាក់ឈ្មោះ Ruth Shadyៗ[៣]

នៅមុនពេលពុំទាន់មានការធ្វើកំណាយនៅទីនេះ អ្នកស្រាវជ្រាវគិតនៅថាអរិយធម៌កកើតឡើងដំបូងៗនៅលើពិភពលោកមានត្រឹម៥តែប៉ុណ្ណោះ ប៉ុន្តែលទ្ធផលនៃការធ្វើកំណាយបានបង្ហាញថា អរិយធម៌ដែលកកើតឡើងដំបូង គឺមានរហូតដល់ទៅ៦ឯណោះ មេសូប៉ូតាមី អេហ្ស៊ីប ឥណ្ឌាស ចិន និង ខារ៉ាល រួមបញ្ចូលទាំងអរិយធម៌ខារ៉ាលផងដែរៗ[៤]

តាមរយៈការរកឃើញ និងធ្វើកំណាយនៅប្រាសាទពីរ៉ាមីត ខារ៉ាល លោកស្រី Ruth Shady ដែលជាប្រធានគម្រោងស្រាវជ្រាវខារ៉ាល និងអ្នកស្រាវជ្រាវជនជាតិអាមេរិកឈ្មោះ Jeff Rose បានអះអាថា អរិយធម៌ខារ៉ាល គឺជាអរិយធម៌ដែលមានអាយុកាលចាស់ជាងគេនៅក្នុងតំបន់អាមេរិក បន្ទាប់ពីបានធ្វើការវិភាគកាបូន១៤ គឺមានអាយុកាលប្រហាក់ប្រហែលគ្នាទៅនឹងប្រាសាទពីរ៉ាមីតគីសា (Pyramid of Giza) នៅអេហ្ស៊ីប ពោលគឺមានអាយុកាល២៦២៧ឆ្នាំមុនគ.ស.រហូតដល់២០០០ឆ្នាំមុនគ.ស.ៗ[៥] លោក Jeff Rose បានបង្ហាញថាការរៀបចំ

---

[១] https://whc.unesco.org: Sacred City of Caral-Supe

[២] Pérou : Caral, cité archéologique vieille de 5000 ans, menacée par des constructions illégales (rtbf.be)

[៣] https://www.history.com/news/caral-peru-norte-chico-oldest-civilization-western-hemisphere

[៤] https://www.france.tv/documentaires/science-sante/905505-perou-la-cite-perdue-de-caral.html

[៥] https://www.history.com/news/caral-peru-norte-chico-oldest-civilization-western-hemisphere

អត្ថបទដោយ៖ អេង តុលា

គ្រឹះប្រាសាទពីរ៉ាមីត ខារ៉ាល គឺប្រើបច្ចេកទេសចងជាចង្កោមថ្ម ដាក់ត្រួតលើគ្នាដើម្បីកុំឱ្យមានការរអិលថ្មដែលធ្វើឱ្យសំណង់ប្រាសាទដួលរលំ។[៦] បច្ចេកទេសនៃការកសាងប្រាសាទទាំងនោះ បានបង្ហាញពីការរីកចម្រើនរបស់មនុស្សក្នុងអរិយធម៌ ខារ៉ាល។ លើសពីនេះទៀត អ្នកបុរាណវិទូក៏បានរកឃើញនូវគ្រោងឆ្អឹងមនុស្សពីរផ្សេងៗគ្នាដែលឆ្អឹងមនុស្សទីមួយរកឃើញនៅកណ្ដាលប្រាសាទពីរ៉ាមីត ខារ៉ាល ដែលមានទំហំធំជាងគេ។ តាមរយៈនៃការរកឃើញគ្រោងឆ្អឹងខាងលើ អ្នកបុរាណវិទូបានធ្វើការវិភាគ និងសន្និដ្ឋានថា គ្រោងឆ្អឹងនេះអាចជាការធ្វើពីធីបូជាយញ្ញណាមួយ ដោយសារតែលលាក្បាលពីក្រោយមានស្នាកស្នាមបែកធំ ដែលអាចមានវត្ថុធ្ងន់វាយក្បាលសម្លាប់។[៧] រីឯគ្រោងឆ្អឹងទីពីរ ជាមនុស្សស្រីរកឃើញនៅក្បែរ ប្រាសាទពីរ៉ាមីត រួមមានទាំងគ្រឿងអលង្ការផ្សេងៗ។[៨] អ្នកស្រាវជ្រាវបានចាប់អារម្មណ៍លើបច្ចេកទេសនៃការកសាងប្រាសាទពីរ៉ាមីត ខារ៉ាល និងបច្ចេកទេសនៃការផលិតរូបធ្វើពីដីដុត ព្រោះបើពិនិត្យមើលតាមទីតាំងភូមិសាស្ត្រនៅតំបន់ ខារ៉ាល ជាតំបន់ដីខ្សាច់ ក្ដៅខ្លាំង ដែលខ្វះប្រភពទឹកក្នុងការផលិត និងសម្រាប់ការផ្គត់ផ្គង់ទឹកដល់ជីវភាពរស់នៅរបស់ប្រជាជនខារ៉ាល។[៨]

តាមការសិន្នដ្ឋានរបស់អ្នកស្រាវជ្រាវ លើការសិក្សាសំណង់ប្រាសាទពីរ៉ាមីតទាំងនោះ និងវត្ថុសិល្បៈផ្សេងៗដែលធ្វើពីដីដុត អ្នកស្រាវជ្រាវបានបង្ហាញថា អរិយធម៌នេះមានអាយុកាលប្រហែល៥០០០ឆ្នាំមុនគ.ស.។[៩] ការសិន្នដ្ឋាននេះ គឺបានមកពីការវិភាគកាបូន១៤ដែលបានបង្ហាញពីអាយុកាលនៃទីក្រុងខារ៉ាលនេះ ហើយទីតាំងនៃតំបន់ខារ៉ាលនេះក៏ជាទីក្រុងដែលចាស់ជាងគេនៅក្នុងទ្វីបអាមិក ដែលចាស់ជាងអរិយធម៌នៅតំបន់មេសូអាមេរិក រួមមាន អូលមិច ម៉ាយ៉ា អទិច។[១០] បច្ចុប្បន្នអត្តសញ្ញាណនៃអរិយធម៌ខារ៉ាល គឺជា

[៦] សូមមើល Pérou, la Cité Perdue de Caral | Documentaire

[៧] *Ibid*

[៨] *Ibid*

[៨] *Ibid*

[៩] Sacred City of Caral-Supe - UNESCO World Heritage Centre

[១០] *Ibid*

អត្ថបទដោយ៖ អេង តុលា

សំណង់ប្រាសាទពីរ៉ាមីត ដែលបង្ហាញពីការរស់នៅក្នុងសង្គម សាសនា នយោបាយ និង មានប្រាសាទជាសក្ខីដល់ការគោរពលិទ្ធសាសនាក្នុងសម័យនោះ។




រូបលេខ១៖ ផែនទីនៃតំបន់អរិយធម៌ខារ៉ាល

ប្រភព៖ Minister of Fine art Peru



រូបលេខ២៖ ក្រុមប្រាសាទពីរ៉ាមីត ខារ៉ាល

ប្រភព៖ Google

អត្ថបទដោយ៖ អេង តុលា



រូបលេខ៣៖ ការចងចង្ក្រាមដុំថ្មតូចៗ

ប្រភព៖ https://www.peru-excepcion.com



រូបលេខ៤៖ រូបចម្លាក់ក្នុងអរិយធម៌ខារ៉ាល

ប្រភព៖ https://www.rtbf.be

អត្ថបទដោយ៖ អេង តុលា



រូបលេខ២៥៖ រូបចម្លាក់ក្នុងអរិយធម៌ខារ៉ាល

ប្រភព៖ https://www.rtbf.be



រូបលេខ២៦៖ ប្រាសាទពីរ៉ាមីត ខារ៉ាលដែលមានទំហំធំជាងគេ

ប្រភព៖ Google

អត្ថបទដោយ៖ អេង តុលា



រូបលេខ៧៖ ខាងប្រាសាទពីរ៉ាមីត ខារ៉ាលដែលមានទំហំធំជាងគេ

ប្រភព៖ Google

# ឯកសារយោង


https://whc.unesco.org: Sacred City of Caral-Supe
Pérou : Caral, cité archéologique vieille de 5000 ans, menacée par des constructions illégales (rtbf.be)
https://www.history.com/news/caral-peru-norte-chico-oldest-civilization-western-hemisphere
https://www.france.tv/documentaires/science-sante/905505-perou-la-cite-perdue-de-caral.html
https://www.history.com/news/caral-peru-norte-chico-oldest-civilization-western-hemisphere

Pérou, la Cité Perdue de Caral | Documentaire Pérou, la Cité Perdue de Caral | Documentaire


អត្ថបទដោយ៖ អេង តុលា